ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ......៤០៧...ប.ទ.សជណ.ពក......

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្ទេរការចែកចាយឧបករណ៍តេស្តរហ័សទៅប្រៃសណីយ៍កម្ពុជា

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ មក ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចែកចាយឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ ដែលបានធ្វើឱ្យឧបករណ៍តេស្តរហ័សមានភាពសំបូរនិងបន្សាំទៅនឹងតម្លៃទីផ្សារ ហើយក្រសួង ស្ថាប័ន រោងចក្រ សហគ្រាសនានា និងប្រជាជនទូទៅមានលទ្ធភាពក្នុងការទិញយកទៅធ្វើតេស្ត និងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ផងដែរ។ បច្ចុប្បន្ន ក្រសួងកំពុងចែកចាយឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ **Asan Easy Test ផលិតនៅប្រទេសកូរ៉េ និង Wondfo ផលិតនៅប្រទេសចិន** ជូនក្រសួង-ស្ថាប័ន ក្រុមហ៊ុន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរងភ្នាក់ងារចែកចាយ និងសាធារណជន។

ចាប់ពី**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១** នេះតទៅ ក្រសួងនឹងផ្ទេរការចែកចាយឧបករណ៍តេស្តរហ័សទាំងពីរប្រភេទនេះទៅប្រៃសណីយ៍កម្ពុជា ដើម្បីបន្តចែកចាយ និងអាចផ្តល់បន្ថែមនូវសេវាកម្មដឹកជញ្ជូន។ សម្រាប់សាធារណជនដែលបានបញ្ជាទិញនិងទូទាត់រួចមុនកាលបរិច្ឆេទខាងលើ សូមមកទទួលឧបករណ៍តេស្តរហ័សនៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ដូចនេះ ក្រសួង-ស្ថាប័ន ក្រុមហ៊ុន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរងភ្នាក់ងារចែកចាយ និងសាធារណជនអាចបន្តបញ្ជាទិញឧបករណ៍តេស្តរហ័សតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលធ្លាប់ប្រើប្រាស់ពីមុនមក មានតំណភ្ជាប់ **mptc.gov.kh/rt** ឬ **អញ្ជើញទិញដោយផ្ទាល់នៅប្រៃសណីយ៍កម្ពុជា** ដែលមានអាសយដ្ឋាន វិថីព្រះអង្គអេង (១៣) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទូរសព្ទលេខ ០៩៦ ៦៥៩ ២៧៣៣/ ០១៥ ២៧៩ ៩២៧ ជារៀងរាល់ម៉ោងធ្វើការ ឬតាមដានទំព័រហ្វេសបុករបស់ប្រៃសណីយ៍កម្ពុជា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១

អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីមែល : info@mptc.gov.kh